**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាយកសណ្ឋាគារ ហ្គាខិន ស៊ីធី**

លេខបញ្ជីពាណិជ្ជកម្ម ៖០០០២៨៣៩១

លេខអត្តសញ្ញាណសហគ្រាស ប.ស.ស ៖ ១០០៩០៥៧៥

អាស័យដ្ឋាន៖ #មហាវិថីវិមាន ឈ្នះ ឈ្នះភូមិព្រែកតាវ័ត្ត សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានី ភ្នំពេញ។

**សូមគោរពជូន**

**លោកប្រធាននាយកអធិការកិច្ចការងារ**

**កម្មវត្ថុ៖** សំណើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិកចំនួន២៦នាក់រយះពេល១៥ថ្ងៃ។

**យោង៖** មាត្រា៧១និងមាត្រា៧២នៃច្បាប់ស្តីពីការងារ របស់ព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោកប្រធាន មេត្តាជ្រាបថាដោយសារតែមានការផ្ទុះឡើងនូវជំងឺ កូវីត១៩ (Covid 19)ធ្វើអោយអតិថិជនរបស់ក្រុមហ៊ុនយើងខ្ញុំបានធ្វើការលុបចោលនូវកម្មវិធីប្រជុំផ្សេងៗនិងការកក់បន្ទប់ស្នាក់នៅដែលជាហេតុធ្វើអោយមានផលប៉ះពាល់យ៉ាងខ្លាំងចំពោះក្រុមហ៊ុនយើងខ្ញុំ។ហេតុដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន២៥នាក់ក្នុងចំណោមកម្មករនិយោជិកសរុបចំនួន២១៣នាក់រយះពេល១៥ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០។

ក្នុងអំឡុងពេលពេលនៃការព្យួរកិច្ចសន្យាការងារបុគ្គលិកចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ សណ្ឋាគារយើងបានត្រៀមត្រៀងផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិកចំនួនស្មើរនឹង ៥០%នៃប្រាក់ឈ្នួលគោល។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម លោកប្រធាន មេត្តាពិនិត្យនិងសម្រេចដោយក្តីអនុគ្រោះ។

សូម លោកប្រធាន មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញថ្ងៃទី២៨ខែមិថុនាឆ្នាំ២០២០

ហត្ថលេខានាយកក្រុមហ៊ុន

CITY HOTEL
HUMAN RESOURCES DEPARTMENT

ជូនភ្ជាប់មកជាមួយ៖

-កិច្ចព្រមព្រៀងរវាងកម្មករនិយោជិតជាមួយនិយោជក

-វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចំលង)ចំនួន៣ច្បាប់

-បណ្ណពន្ធប៉ាតង់ច្បាប់(ថតចំលង)ចំនួន៣ច្បាប់

-វិញ្ញាបនបត្របញ្ជិការសហគ្រាស ត្រឹះស្ថាន ក្នុងប.ស.ស ចំនួន៣ច្បាប់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# នាយកសណ្ឋាគារ ហ្គាឌិន ស៊ីធី
## កិច្ចព្រមព្រៀង

ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០ នៅ **សណ្ឋាគារ ហ្គាឌិន ស៊ីធី** បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាព លោកស្រី ឌុក ស្រីវត្ថ ជាតំណាងក្រុមហ៊ុន ស្តីពីការព្យួរកិច្ចសន្យាការងារមួយរយះដោយមូលហេតុនៃការផ្ទុះឡើងនូវជំងឺ កូវីត១៩ (Covid 19) ដែលជាហេតុធ្វើអោយមានផលប៉ះពាល់យ៉ាងខ្លាំងចំពោះក្រុមហ៊ុនដោយធ្វើអោយអតិថិជនរបស់ក្រុមហ៊ុនការយើងធ្វើការលុបចោលកម្មវិធីប្រជុំផ្សេងៗនិងការកក់បន្ទប់ស្នាក់នៅ។

សមាសភាពចូលរួម៖

១-ភាគីតំណាងក្រុមហ៊ុន

-លោកស្រី ឌុក ស្រីវត្ថ តំណាងអោយភាគីក្រុមហ៊ុន

-លោកស្រី ទៀប ណារីយ៉ា អ្នកកត់ត្រា

២-ភាគីតំណាងកម្មករនិយោជិក

-លោក ស្តើង លី ជាប្រតិភូបុគ្គលិក

-កញ្ញា ហុង ធាវី ជាប្រតិភូបុគ្គលិក

ក្រោយពីបានពិភាក្សាគ្នាយ៉ាងផ្ចិតល្អិតរួចមកភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោម៖

១-ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន២៦នាក់ដោយគិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០រហូតដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០។

២-ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារប្រតិភូបុគ្គលិកបានព្រមព្រៀងផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិកចំនួនស្មើរនឹង៥០%នៃប្រាក់ឈ្នួលគោល។

៣-ចប់ការព្យួរការងារកម្មករនិយោជិតត្រូវមកធ្វើការងារនៅកន្លែងដើមវិញទៅតាមតួនាទីភារកិច្ចរបស់ខ្លួន។

ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១០:៣០នាទី នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ដដែលក្រោមបរិយាកាសសប្បាយរីករាយ។

GARDEN CITY HOTEL
HUMAN RESOURCES DEPARTMENT

ថ្ងៃពុធ ៩កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៤ខែមិថុនា ឆ្នាំ២០២០

បានឃើញ និងឯកភាព
ជ. តំណាងនាយកក្រុមហ៊ុន

GARDEN CITY HOTEL
HUMAN RESOURCES DEPARTMENT

បានឃើញ និងឯកភាព
តំណាងកម្មករនិយោជិត

-លោក ស្មើង លី ជាប្រតិភូបុគ្គលិក

-កញ្ញា ហុង ផារី ជាប្រតិភូបុគ្គលិក